ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៤
ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩
សាលដីកា
លេខ ៣៩ VIII
ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម (របាយការណ៍)

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកស្រី [redacted] ទញ្ញារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] យ៉ាំងខៃគ ឬ ( ដាំ ខេគ ) ចំពោះសាលដីកាលេខ ៦៤ “ស.ស ក្រVII.ធ” ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានបុគ្គលពាក់ព័ន្ធគឺ



Scanned with CamScanner

ជនត្រូវចោទឈ្មោះ [redacted] យ៉ាំងខែត ឬ ( ដាំ ខេត ) ភេទប្រុស កើតថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៦ ជាតិខ្មែរ មុខរបរ ជួយលក់ត្រីម្តាយ កម្រិតវប្បធម៌រៀនថ្នាក់ទី០២ មានទីកន្លែងកំណើតនៅភូមិលូ សង្កាត់ស្ទាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ ទីលំនៅមុនពេលចាប់ខ្លួន [redacted] រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ជាអនីតិជន ។ ទោសពីមុនគ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០២៣២ ដ.ឃ.ដ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ។ បច្ចុប្បន្នកំពុងជាប់ឃុំខ្លួន នៅពន្ធនាគារម២ ។

-មានលោកស្រីមេធាវី [redacted] នីមឆាយ ជាអ្នកការពារ ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវបេតុង ក្រុម៧ ភូមិលូ សង្កាត់ស្ទាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ២២ យប់ កម្លាំងអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ បានបើកកិច្ចប្រតិបត្តិការស្រាវ ឈានដល់ការបង្ក្រាបជាក់ស្តែងនៅចំណុចផ្លូវបេតុង ក្រុមទី៧ ភូមិលូ សង្កាត់ស្ទាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឃាត់ខ្លួនបានជនត្រូវចោទឈ្មោះ ឌុក យ៉ាំងខែត (ដាំ ខេត) កំពុងឈរលក់ថ្នាំញៀនឱ្យម៉ូយ ។ បន្ទាប់មកសមត្ថកិច្ចក៏ធ្វើការឆែកឆេរលើជនត្រូវចោទ ឃើញមានថ្នាំញៀនប្រភេទមេតំហ្វេតាមីនចំនួន ៣៤ កញ្ចប់ ក្នុងនោះមានចំនួន ០២ កញ្ចប់ថង់ធំ សរុបមានទម្ងន់ ៤៦,៧១ក្រាម ថង់ប្លាស្ទីកសម្រាប់ច្រកគ្រឿងញៀនមួយចំនួន និងកាបូបស្ពាយពណ៌ប្រផេះចំនួន ០១ ។ កងកម្លាំងមានសមត្ថកិច្ចក៏នាំខ្លួនឈ្មោះ [redacted] យ៉ាំងខែត (ដាំ ខេត) យកមកធ្វើការសាកសួរ ទើបដឹងថា ថ្នាំញៀនខាងលើនេះគឺជារបស់ឈ្មោះ យូ ភេទប្រុស អាយុ ២៧ ឆ្នាំ ទុកឱ្យជនត្រូវចោទសម្រាប់លក់ ដោយឱ្យលុយចាយក្នុងមួយថ្ងៃៗចំនួន ៣០.០០០ រៀល ។

-បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០២៣២ ដ.ឃ.ដ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ សម្រេចថា ៖

១.ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ [redacted] យ៉ាំងខែត (ដាំ ខេត) ទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួនម២ ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ។

២.ឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនម២ ទទួលនិងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។



Scanned with CamScanner

៣.ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់ ។

-បានឃើញ ពាក្យសុំឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់លោកស្រី [redacted] កញ្ញា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ឃុំងឆត (ដាំ ឆេត) ដែលប្ដឹងមិនសុខចិត្តនឹងដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០២៣២ ដ.ឃ.ដ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៧៧៧៩ "រ" ដ.ព.ស ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

មិនព្រមដោះលែងឱ្យជនត្រូវចោទឈ្មោះ [redacted] ឃុំងឆែត (ដាំ ឆេត) ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរជួយលក់ត្រីឱ្យម្ដាយ កម្រិតវប្បធម៌មិនចេះអក្សរ ទីកន្លែងកំណើតនៅភូមិលូ សង្កាត់ស្ទឹងមានជ័យ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានអាសយដ្ឋានមុនពេលឃាត់ខ្លួនស្នាក់នៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ជាអនីតិជន ។

ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវបេតុង ក្រុម៧ ភូមិលូ សង្កាត់ស្ទឹងមានជ័យ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់លោកស្រី [redacted] កញ្ញា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ឃុំងឆែត (ដាំ ឆេត) ដែលប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៧៧៧៩ "រ" ដ.ព.ស ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សាលដីកាសភាស៊ើបសួរលេខ ៦៤ សស.ក្រVII (ធ) ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់មេធាវី [redacted] កញ្ញា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៧៧៧៩ "រ" ដ.ព.ស ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣.សាលដីកានេះ ប្រកាសជាអសាធារណៈ នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកស្រី [redacted] កញ្ញា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] យ៉ាំងខែត (ដាំ ខេត) ចំពោះសាលដីកាលេខ ៦៤ សស.ក្រVII (ធ) ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំដោយលើកឡើងដូចខាងក្រោមថា៖

យល់ឃើញថា ជនត្រូវចោទសុំនៅក្រៅឃុំ ហើយសំអាងថា ទើបតែអាយុ ១៣ (ដប់បី) ឆ្នាំ ប៉ុន្តែបើពិនិត្យមើលក្នុងសៀវភៅគ្រួសារ ហើយឪពុកម្តាយបញ្ជាក់ថាឈ្មោះ [redacted] ដេត កើតនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០២ ដែលមានអាយុ ១៧ (ដប់ប្រាំពីរ) ឆ្នាំ ហើយ ។

ហេតុដូចនេះ ការសម្រេចរបស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ ។ ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ៖

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកស្រី [redacted] កញ្ញា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ ឌុក យ៉ាំងខែត (ដាំ ខេត) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៤ សស.ក្រ.VII. (ធ) ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

-លោកស្រី [redacted] គឹមឆាយ ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ាំងខែត (ដាំ ខេត) បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនទើបមានអាយុតែ ១២ ឆ្នាំ តែប៉ុណ្ណោះ តាមរយៈពាក្យសុំដោះលែងឱ្យនៅក្រៅឃុំរបស់មេធាវីការពារ ក៏បានភ្ជាប់មកនូវសំបុត្រកំណើត ព្រមទាំងចៅសង្កាត់បញ្ជាក់ច្បាស់លាស់ថា កូនក្តីរបស់ខ្លួនទើបតែមានអាយុជាង ១៣ ឆ្នាំ ពិតប្រាកដមែន។ តាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងសិទ្ធិកុមារ កូនក្តីរបស់ខ្លួនគួរតែបាននៅក្រៅឃុំ ព្រោះប៉ះពាល់ដល់សិទ្ធិនិងសេរីភាព ។

សំណូមពរ៖ ស្នើសុំឱ្យតុលាការអនុញ្ញាតឱ្យកូនក្តីរបស់ខ្លួនបាននៅក្រៅឃុំជាបណ្តោះអាសន្ន ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងប្តឹងសុំរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទឈ្មោះ [redacted] ខេត ឬ [redacted] យ៉ាំងខែត
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនត្រូវចោទ
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

## សំអាងហេតុ
## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកស្រីមេធាវី [redacted] កញ្ញា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ខេត (ឌុក ឃុំងខេត) ធ្វើឡើងពុំស្របតាមបទប្បញ្ញត្តិមាត្រា ៤២២ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ដោយហេតុថា បណ្តឹងសាទុក្ខនេះរបស់មេធាវី [redacted] កញ្ញា ធ្វើឡើងដោយពុំមានលិខិតផ្ទេរសិទ្ធិឱ្យមេធាវីក្នុងការប្តឹងសាទុក្ខពីសំណាក់ជនត្រូវចោទ ឬអាណាព្យាបាលជនត្រូវចោទឡើយ ។ បទប្បញ្ញត្តិមាត្រា ៤២២ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តិថា "*ជនជាប់ចោទ ពិរុទ្ធជន និងបុគ្គលដែលត្រូវគេទាមទារក្នុងក្របខណ្ឌនីតិវិធីបត្យាប័ន អាចតំណាងដោយមេធាវី ។ មេធាវីត្រូវមានលិខិតផ្ទេរសិទ្ធិឱ្យប្តឹងសាទុក្ខ*" ។.............................។ ហេតុដូច្នេះ តុលាការកំពូលគប្បីសម្រេចលើកចោលបណ្តឹងសាទុក្ខនេះ ដោយមិនចាំបាច់លើកយកមកពិនិត្យ ពិចារណានូវ សេចក្តីសន្និដ្ឋានរបស់ភាគីពាក់ព័ន្ធឡើយ ។

## ហេតុដូច្នេះ
## សម្រេចសេចក្តី

១-លើកចោលបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកស្រី [redacted] កញ្ញា ដោយមូលហេតុធ្វើឡើងខុសនឹងទម្រង់ច្បាប់ ។

២-តម្កល់សាលដីកាលេខ ៦៤ សស.ក្រVII(ធ) ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃពុធទី១៩ ខែកុម្ភៈ ឆ្នាំ២០២០៕

Scanned with CamScanner